JICA កម្ពុជា

គំរោងពង្រឹងប្រព័ន្ធអភិវឌ្ឍន៍ធនធានមនុស្សវិស័យសុខាភិបាល

The Project for Strengthening Human Resources Development System of Co-medicals

ព្រឹត្តប័ត្រព័ត៌មានពីគំរោង HRD JICA លេខ ៣ ខែកញ្ញា ឆ្នាំ២០១០

# ការបណ្តុះបណ្តាលដៃគូនៃគំរោងនៅប្រទេសជប៉ុន

ក្រុមការងារគំរោងបានបញ្ជូនមន្ត្រីសុខាភិបាល ចំនួន ៣ រូបសំរាប់ចូលរួមក្នុងការបណ្តុះបណ្តាលដៃគូ (Counterpart Training) នៅប្រទេសជប៉ុនដែលមានវត្តមាន: ឯកឧត្តមសាស្ត្រាចារ្យ ធា គ្រុយ រដ្ឋលេខាធិកាក្រសួងសុខាភិបាល ឯកឧត្តមសាស្ត្រាចារ្យ អ៊ឹ សុផល សកលវិទ្យាធិការនៃសកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល លោកស្រី គាត ភួង ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស នៃក្រសួងសុខាភិបាល។ ប្រធានបទនៃការបណ្តុះបណ្តាលមាន ដូចជា "ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន" "ប្រព័ន្ធផ្តល់វិញ្ញាបនប័ត្រ" "ដំនើរការនៃការអភិវឌ្ឍន៍ មូលដ្ឋានច្បាប់សំរាប់ការអភិវឌ្ឍន៍ធនធានមនុស្ស" ដែលបានប្រព្រឹត្តទៅនៅតាមវិទ្យាស្ថានជាប់ពាក់ព័ន្ធ ដូចជា មជ្ឈមណ្ឌលជាតិ សុខភាពសកល និង វេជ្ជសាស្ត្រ មហាវិទ្យាល័យជាតិគិលានុបដ្ឋាក សមាគមន៏គិលានុបដ្ឋាកនៃប្រទេសជប៉ុន និង ក្រសួងសុខាភិបាល ការងារ និង សុខាមាលភាព។ មន្ត្រីដែលបានចូលរួមនឹងធ្វើការរាយការណ៍អំពីការបណ្តុះបណ្តាលនេះនៅក្នុងការប្រជុំគណៈកម្មការសម្របសម្រួលគំរោង លើកទី ១ ដែលនឹងប្រព្រឹត្តទៅនៅ ខែតុលា ឆ្នាំ ២០១០។

### រូបភាពខ្លះៗ ក្នុងពេលបណ្តុះបណ្តាល










# ការប្រជុំថ្នាក់ជាតិ និង ការប្រជុំភូមិភាគប្រចាំត្រីមាស

មានការប្រជុំជាច្រើនទាក់ទងនឹងសកម្មភាពអភិវឌ្ឍន៍ធនធានមនុស្សដែលបានរៀបចំក៏ដូចជារៀបចំរួមដោយនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្សនៃក្រសួងសុខាភិបាល។

ក្នុងការប្រជុំទាំងនោះ ការប្រជុំថ្នាក់ជាតិប្រចាំត្រីមាសជាការប្រជុំមួយដ៏សំខាន់ក្នុងចំណោមការប្រជុំដទៃទៀត។ ការប្រជុំប្រចាំត្រីមាសថ្នាក់ជាតិបានប្រព្រឹត្តទៅ នៅថ្ងៃទី២០ ទី២១ និង ទី២២ ខែកញ្ញា ឆ្នាំ ២០១០ នៅនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្សក្រសួងសុខាភិបាល ដែលដឹកនាំដោយនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និង មានការចូលរួមពីសំនាក់សាលាមធ្យមសិក្សាភូមិភាគទាំង៤ សកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និង សាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ។ ក្រៅពីនេះម្ចាស់ជំនួយអន្តរជាតិ ដូចជា JICA, UNFPA, GTZ ដែលចូលរួមចំនែកក្នុងការអភិវឌ្ឍន៍ធនធានមនុស្សក៏មានវត្តមានក្នុងការប្រជុំនេះផងដែរ ។ ប្រធានបទដែលគេបានលើកឡើងមកពិភាក្សា ក្នុងការប្រជុំថ្នាក់ជាតិប្រចាំត្រីមាសនេះមានដូចជា ការណែនាំឱ្យស្គាល់ពីគំរោងអភិវឌ្ឍន៍ធនធានមនុស្សរបស់ JICA ការរាយការណ៍អំពីដំនើរ ការនៃការបង្កើតសមត្ថភាពជំនាញ (Core Competency) របស់ឆ្មបដោយគណៈឆ្មប ការគ្រប់គ្រងទិន្នន័យកំរងសំនួរចំឡើយ របស់ថ្នាក់បរិញ្ញាប័ត្ររងគិលានុបដ្ឋាក កាលវិភាគនៃការប្រឡងបញ្ចប់ការសិក្សាផ្នែកគិលានុបដ្ឋាក ។

រីឯការប្រជុំមួយទៀតគឺ ការប្រជុំភូមិភាគបែងចែកជា២គឺ "ការប្រជុំក្រុមប្រឹក្សាបច្ចេកទេស" និង "ការប្រជុំក្រុមប្រឹក្សាសម្របសម្រួលការបណ្តុះបណ្តាល" ដែលបានប្រព្រឹត្តទៅរួមគ្នានៅថ្ងៃទី២២ និង ២៣ ខែកញ្ញា ឆ្នាំ២០១០ នៅខេត្តស្វាយរៀង។ ប្រធានបទនៃ "ការប្រជុំក្រុមប្រឹក្សាបច្ចេកទេស" គឺដើម្បីពិភាក្សាអំពីការអនុវត្តន៍ជំនាញគ្លីនិកនៃសាលាមធ្យមសិក្សាភូមិភាគនៅតាមមន្ទីរពេទ្យបង្អែក និង បញ្ហាមួយចំនួនដែលកំពុងជួបប្រទះ។ ប្រធានបទនៃ "ការប្រជុំសម្របសម្រួលការបណ្តុះបណ្តាល" គឺដើម្បីធ្វើការពិនិត្យសាឡើងវិញទៅលើការបណ្តុះបណ្តាលមួយចំនួនដែលបានអនុវត្តន៍ទៅនៅត្រីមាសកន្លងមក បានធ្វើការរាយការណ៍ដោយមន្ទីរសុខាភិបាលខេត្ត។

នៅក្នុង "ការប្រជុំក្រុមប្រឹក្សាបច្ចេកទេស" នៅខេត្តស្វាយរៀងការពិភាក្សាបានលើកឡើងពីបញ្ហា ដែលកំពុងជួបប្រទះនៅពេលចុះកម្មសិក្សានៅតាមមន្ទីរពេទ្យបង្អែក ។ ដោយហេតុថា គំរោងរបស់ JICA ភាគច្រើនប្រព្រឹត្តទៅនៅក្រសួងសុខាភិបាល មានន័យថាគំរោងស្ថិតនៅឆ្ងាយពីកន្លែងអនុវត្តន៍។ ដូច្នេះដើម្បីដោះស្រាយបញ្ហាទាំងនេះ ជាការសំខាន់ណាស់ដែលយើងស្តាប់នូវបញ្ហាជាក់ស្តែងដែលសាលាភូមិភាគ ក៏ដូចជា មន្ទីរពេទ្យកំពុងជួប និង ដើម្បីទទួលនូវព័ត៌មានត្រឡប់ និង ផ្តល់ជាអន្តរគមន៏របស់គំរោងទៅខាងមន្ទីរពេទ្យ។ ជាទីបញ្ចប់ ភាគីគំរោងសង្ឃឹមយ៉ាងមុតមាំក្នុង ការចូលរួមការប្រជុំទៀងទាត់ឱ្យបានច្រើន តាមដែលអាចទៅរួច។





**រូបភាពខាងឆ្វេង: ការប្រជុំក្រុម ប្រឹក្សា-បច្ចេកទេស រូបភាពខាងស្តាំ: មន្ទីរ-សុខាភិបាលខេត្តស្វាយរៀង**

សូមទៅកាន់គេហទំព័ររបស់គំរោងតាមរយៈអាស័យដ្ឋានខាងក្រោម :
http://www.jica.go.jp/project/cambodia/004/index.html